

2025

របាយការណ៍

# ការប្រែប្រួលវត្តមានដើមច្យោះ

## នៅដែនជម្រកសត្វព្រៃព្រះរការក្នុងរយៈពេល ១ទសវត្សចុងក្រោយ

PED
PARTNERSHIP
FOR ENVIRONMENT
AND DEVELOPMENT
ORGANIZATION

# មាតិកា

បញ្ជីរូបភាព .......... 4

បញ្ជីតារាង.......... 4

បញ្ជីអក្សរកាត់.......... 4

ពាក្យគន្លឹះ .......... 4

អំពីPED Cambodia .......... - 5 -

សេចក្តីសង្ខេប.......... - 6 -

១. សេចក្តីផ្តើម .......... - 8 -

១.១. ចំណោទបញ្ហា .......... - 9 -

១.២.និយមន័យ៖ ច្បោះជាអ្វី? .......... - 10 -

១.៣ ប្រវត្តិដែនជម្រកសត្វព្រៃព្រះរការ .......... - 12 -

២. គោលបំណងនៃការសិក្សាស្រាវជ្រាវ និងវិសាលភាព.......... - 14 -

៣. វិធីសាស្ត្រស្រាវជ្រាវ.......... - 14 -

៤.លទ្ធផលនៃការស្រាវជ្រាវ .......... - 15 -

៤.១ លទ្ធផលជំនួបជាមួយសមាជិកសហគមន៍ដែលមានដើមច្បោះ .......... - 15 -

៤.២ វត្តមានដើមច្បោះ.......... - 15 -

៤.៣ កត្តាដែលនាំឱ្យបាត់បង់ដើមច្បោះ .......... - 16 -

៤.៤ ទំ នាក់ទំនងដើមច្បោះ និងជីវភាពប្រជាជន ..................................... - 18 -
៤.៥ ការពិភាក្សាលើស្ថានភាពគម្របព្រៃឈើឆ្នាំ២០១៥ និងឆ្នាំ២០២៣ ......... - 19 -
៥.សន្និដ្ឋាន..................................................................................................... - 24 -
៦.អនុសាសន៍ ................................................................................................ - 26 -
ឯកសារយោង .................................................................................................. - 27 -

## បញ្ជីរូបភាព

រូបភាពទី 1 ការដុតរន្ធច្បោះដើម្បីយកជ័រ ........................................................- 7 -

រូបភាពទី 2  ជនជាតិដើមភាគតិចកួយកំពុងជងជ័រទឹក ........................................- 11 -

រូបភាពទី 3 ពីដុងឬកានសម្រាប់ដាក់ជ័រច្បោះពេលកំពុងប្រមូលផល ............................- 13 -

រូបភាពទី 4 ក្រាបបង្ហាញពីការប្រែប្រួលវត្តមានដើមជ័រទឹករយៈពេល១ទសវត្សរ៍...............- 16 -

រូបភាពទី 5 ការកាប់បំផ្លាញព្រៃឈើនៅក្នុងដែនជម្រកសត្វព្រៃព្រះរការ ........................- 18 -

រូបភាពទី 6 គុយដែលសហគមន៍ធ្លាប់ប្រមូលផលចេញពីដែនជម្រកសត្វព្រៃព្រះរការ .........- 17 -

រូបភាពទី 7 ការប្រៀបធៀបគម្របព្រៃឈើឆ្នាំ២០១៥ និងឆ្នាំ២០២៣ ...........................- 21 -

រូបភាពទី 8 សហគមន៍ចុះពិនិត្យមើលពីការទន្ទ្រានដីព្រៃ.........................................- 22 -

រូបភាពទី 9 ផែនទីបង្ហាញដែនជម្រកសត្វព្រៃឆែប ព្រះរការ .....................................- 24 -

## បញ្ជីតារាង

តារាង 1 ចំនួនសំណាកដែលបានសម្ភាសន៍..............................................- 15 -

## បញ្ជីអក្សរកាត់

FGD: Focus Group Discussion (ការពិភាក្សាក្រុម)

KIIs: Key Informant Interviews (ការសម្ភាន៍ជនបង្គោល)

ODC: Open Development Cambodia (អង្គការទិន្នន័យអំពីការអភិវឌ្ឍ)

## ពាក្យគន្លឹះ

អាជីវកម្មព្រៃគុប សំដៅលើក្រុមហ៊ុនដែលទទួលបានដីសម្បទានសេដ្ឋកិច្ច។

## អំពីPED Cambodia

អង្គការភាពជាដៃគូដើម្បីបរិស្ថាន និងការអភិវឌ្ឍគឺជាស្ថាប័នមិនរកប្រាក់ចំណេញថ្មីមួយ ត្រូវបានចុះបញ្ជី និងទទួលស្គាល់ដោយក្រសួងមហាផ្ទៃនៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៤ ដែលមានស្ថាបនិកជាក្រុមអ្នកការពារបរិស្ថានជួរមុខនៅក្នុងប្រទេសកម្ពុជា។ បេសកកម្មរបស់ពួកយើងគឺដើម្បីពង្រីកការចូលរួមរបស់សាធារណជននៅក្នុងកិច្ចការពារ បរិស្ថាន លើកកម្ពស់សេរីភាពសម្តែងមតិ និងការពារដល់អ្នកការពារបរិស្ថាន និងសិទ្ធិមនុស្ស។ ថ្វីដ្បិតតែពួកយើងជាស្ថាប័នថ្មី ក៏ប៉ុន្តែការងាររបស់ពួកយើងទទួលបាននូវការទទួលស្គាល់ពីសំណាក់ប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុក និងអន្តរជាតិយ៉ាងទូលំទូលាយ តាមរយៈការចូលរួមចំណែករបស់ពួកយើងទៅកាន់សង្គម ដែលរាប់ចាប់តាំងពីឆ្នាំ២០១៨ នៅពេលដែលពួកយើងធ្វើការងារក្នុងនាមជាក្រុមចលនាយុវជនដើម្បីបរិស្ថាន។

យើងមានបេសកកម្មគាំពារ និងអភិវឌ្ឍន៍សមត្ថភាពរបស់បណ្តាញសហគមន៍ យុវជន និងប្រជាពលរដ្ឋ ដើម្បីពង្រឹងការចូលរួមក្នុងការអភិវឌ្ឍសង្គមតាមបែបប្រជាធិបតេយ្យ និងបរិយាបន្ន។ ដើម្បីសម្រេចបាននូវបេសកកម្មនេះ អង្គការPEDផ្តល់ជូននូវវគ្គបណ្តុះបណ្តាល កម្មវិធីបោះជំរំ សិក្ខាសាលា ដល់ក្រុមគោលដៅរបស់យើងដើម្បីឱ្យពួកគាត់យល់ដឹងអំពីសិទ្ធិជាមូលដ្ឋានរបស់ខ្លួន គោលនយោបាយគាំពារ បរិស្ថាន ព្រមទាំងគោលការណ៍សំខាន់ៗនៃសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យផងដែរ។

អង្គការPEDក៏ផ្តល់ជំនួយបច្ចេក ទេសដល់អ្នកការពារបរិស្ថានជួរមុខ និងសហគមន៍មូលដ្ឋាន ព្រមទាំងចុះឃ្លាំមើល និងចងក្រងនូវរបាយការណ៍ សហការរៀបចំសកម្មភាពតស៊ូមតិ ព្រឹត្តិការណ៍ និងការរៀបចំកម្មវិធីនានាទាំងកម្រិតអនឡាញ និងដោយផ្ទាល់។

### តាមដានពួកយើងតាមរយៈ

www.ped-cambodia.org

Email: ed@ped-cambodia.org

## សេចក្តីសង្ខេប

តំបន់ដែនជម្រកសត្វព្រៃព្រះរការ មានទំហំ ៩០៣៦១ហិកតា ហ៊ុមព័ទ្ធដោយស្រុកចំនួន០៣គឺ ស្រុកត្បែងមានជ័យ ស្រុកឆែប និងស្រុកជាំក្សាន្តនៃខេត្តព្រះវិហារ។ តំបន់នេះត្រូវបានដាក់បញ្ចូលជាដែនជម្រកសត្វព្រៃព្រៃព្រះរការនៅថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៦ យោងតាមអនុក្រឹត្យលេខ៧៥ អនក្រ.បក ។

ជនជាតិដើមភាគតិចកួយភាគច្រើនរស់នៅពឹងអាស្រ័យលើការទាញយកផល-អនុផលព្រៃឈើចេញពីតំបន់ដែនជម្រកសត្វព្រៃព្រះរការ។ ផល-អនុផលព្រៃឈើរួមមានការរកឃ្មុំ បេះផ្លែគុយ ផ្លែសិរមាន់ ផ្តៅ គមសោម គមផ្អាវ និងបន្លែព្រៃផ្សេងទៀតជាអាហារ។ ជាពិសេសគ្រួសារនីមួយៗនៃជនជាតិដើមភាគតិចកួយគឺពឹងអាស្រ័យសំខាន់ទៅលើការជងជ័រច្បោះ ចេញពីដើមឈើទាល និងត្រាច។ តាមរយៈការសម្ភាសន៍គ្រួសារនីមួយៗបានឱ្យដឹងថាមានដើមច្បោះយ៉ាងតិចបំផុត២០០ដើម និងគ្រួសារខ្លះទៀតមានច្រើនបំផុតដល់ជាងមួយពាន់ដើម ដែលក្នុងមួយកាន(១កាន=៣០លីត្រ)អាចរកចំណូលបានពី៧ម៉ឺនរៀល ទៅ៨ម៉ឺនរៀល ហើយតាមរដូវខ្លះអាចឡើងដល់១០ម៉ឺន ទៅ១២ម៉ឺនរៀលដែលតម្លៃនេះប្រែប្រួលតាមឈ្មួញកណ្តាលជាអ្នកកំណត់។

ផ្ទុយអំពីអត្ថប្រយោជន៍ដែលសហគមន៍ជនជាតិដើមភាគតិចតែងតែប្រមូលបាន អង្គការទិន្នន័យអំពីការអភិវឌ្ឍ (ODC)បានបង្ហាញថាភាគរយនៃគម្របព្រៃឈើរបស់ប្រទេសកម្ពុជាបានថយចុះបន្តិចពី៤៣,២១ភាគរយក្នុងឆ្នាំ២០១៥ ដល់៣៩,៧៥ភាគរយ ក្នុងឆ្នាំ២០២៣ (ODC, 2023)។ ការប្រែប្រួលនេះក៏បានឆ្លើយតបទៅនឹងការប្រែប្រួលវត្តមានដើមច្បោះក្នុងដែនជម្រកសត្វព្រៃព្រះរការផងដែរ។ ទិន្នន័យនៃបច្ចុប្បន្នភាពគម្របព្រៃឈើនេះ បានបង្ហាញពីការប្រែប្រួលវត្តមានគម្របព្រៃឈើ ដែលហាក់នៅឆ្ងាយពីគ្គីរំពឹងទុកដូចមានចែងក្នុងអាទិភាពទី២ នៃយុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន២០២៣-២០២៨ក្នុងន័យដើម្បីពង្រីកគម្របព្រៃឈើឈានឆ្ពោះទៅគោលដៅ

៦០ភាគរយ នៅឆ្នាំ ២០៥០ (យុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន, ២០២៣)។

ការសិក្សាទៅលើវត្តមានដើមច្បោះនៃតំបន់ដែនជម្រកសត្វព្រៃព្រះរការជាមួយសមាជិកសហគមន៍ដែលអាស្រ័យផ្ទាល់ពីការដងជ័រច្បោះបានបង្ហាញថាវត្តមានដើមច្បោះមានការបាត់បង់ក្រោយពីដាក់បញ្ចូលតំបន់ព្រៃព្រះរការជាដែនជម្រកសត្វព្រៃ។ យោងតាមចំនួនទិន្នន័យដែលទទួលបានចំនួនដើមច្បោះនាពេលបច្ចុប្បន្នមានការថយចុះគួរឱ្យកត់សម្គាល់។

ជាក់ស្តែងចំនួនសំណាកបានបង្ហាញថា ក្នុងឆ្នាំ២០១៥ វត្តមានដើមច្បោះមានចំនួន ១៨ ០៥០ដើម ខណៈពេលដែលនៅក្នុងឆ្នាំ ២០២៤ នៅសល់ត្រឹម១៣ ៦៨០ ដើមតែប៉ុណ្ណោះ។ ទិន្នន័យនេះបានបង្ហាញឱ្យឃើញថាក្នុងរយៈពេលជិតមួយទសវត្សរ៍វត្តមានដើមច្បោះក្នុងដែនជម្រកសត្វព្រៃព្រះរការមានការប្រែប្រួលប្រមាណ២៤ភាគរយដែលស្មើនឹង៤៣៧០ ដើម។ ការប្រែប្រួលនេះកើតចេញពីកត្តាមួយចំនួនដូចជាកត្តាសង្គមរួមមាន បទល្មើសព្រៃឈើខុសច្បាប់ ការទន្ទ្រានដីព្រៃ វាតដីពង្រីកចម្ការ  ព្រមទាំងការដកហូតសម្រាប់ធ្វើលំនៅដ្ឋាន និងកត្តាធម្មជាតិរួមមាន ដួល បាក់ និងឆេះ។

ដើម្បីជាចំណែកចូលរួមក្នុងការការពារព្រៃឈើ ក៏ដូចជារក្សាវត្តមានដើមច្បោះដែលផ្គត់ផ្គង់ដល់ជីវភាពជនជាតិដើមភាគតិចកួយ  និងជាកេរដំណែលសម្រាប់កូនចៅជំនាន់ក្រោយ យើងយល់ថាការបើកលំហសិទ្ធិសេរីភាព ឱ្យមានការចូលរួមក្នុងកិច្ចការថែរក្សា និងអភិរក្សឱ្យបានពេញលេញជាកត្តាដ៏សំខាន់មួយដែលអាជ្ញាធរពាក់ព័ន្ធគួរយកចិត្តទុកដាក់។



*រូបភាពទី 1 ការដុតរន្ធច្បោះដើម្បីយកជ័រ*

# ១. សេចក្តីផ្តើម

ការបង្កើតតំបន់ការពារធម្មជាតិណាមួយត្រូវផ្អែកលើលទ្ធផលនៃការសិក្សាស្រាវជ្រាវ លក្ខណៈពិសេស តម្លៃ និងសក្តានុពលនៃធនធានធម្មជាតិ ជីវៈចម្រុះ ប្រព័ន្ធអេកូឡូស៊ី ទីតាំងប្រវត្តិសាស្ត្រ សេដ្ឋកិច្ច សង្គម និងបរិស្ថាន គោលបំណងនៃការគ្រប់គ្រង សិទ្ធិប្រើប្រាស់ធនធានធម្មជាតិ និងកត្តាពាក់ព័ន្ធផ្សេងទៀតព្រមទាំងគោលនយោបាយ និងយុទ្ធសាស្ត្ររបស់រដ្ឋាភិបាល (ក្រសួងបរិស្ថាន និងធនធានធម្មជាតិ, 2023)។ ជាក់ស្តែងប្រទេសកម្ពុជាពោរពេញដោយធនធានធម្មជាតិយ៉ាងសម្បូរបែបទាំងលើគោក ក្នុងទឹក និងក្រោមដី។ ធនធានធម្មជាតិទាំងនេះត្រូវបានការពារដោយច្បាប់ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដែលបានក្លាយជាតំបន់ការពារធម្មជាតិ។

តំបន់ការពារធម្មជាតិ ត្រូវបានបែងចែកជា ៩ ប្រភេទ រួមមាន៖

១. ឧទ្យានជាតិ

២. ឧទ្យានជាតិសមុទ្រ

៣. ដែនជម្រកសត្វព្រៃ

៤. តំបន់ការពារទេសភាព

៥. តំបន់ប្រើប្រាស់ច្រើនយ៉ាង

៦. តំបន់រ៉ាមសារ

៧. តំបន់ស្នូលនៃបបរីយជីវមណ្ឌល

៨. តំបន់បេតិកភណ្ឌធម្មជាតិ

៩. ប្រភេទតំបន់ការពារធម្មជាតិផ្សេងទៀត។

តំបន់ការពារធម្មជាតិនីមួយៗបែងចែកចេញជា ០៤តំបន់គ្រប់គ្រងដូចខាងក្រោម៖

១. តំបន់ស្នូល៖ គឺជាតំបន់គ្រប់គ្រងដែលមានតម្លៃខ្ពស់សម្រាប់ការអភិរក្សប្រភេទសត្វ រុក្ខជាតិដែលកម្រជិតផុតពូជ ទទួលរងគ្រោះថ្នាក់ គំរាមកំហែង ទីតាំងសត្វព្រៃបន្តពូជ និងប្រព័ន្ធអេកូឡូស៊ីផុយស្រួយ។

២. តំបន់អភិរក្ស៖ គឺជាតំបន់គ្រប់គ្រងស្ថិតនៅជាប់នឹងតំបន់ស្នូលដែលមានតម្លៃខាងការអភិរក្សធនធានធម្មជាតិ

ប្រព័ន្ធអេឡូស៊ី តំបន់ទីជម្រាល និងតំបន់ដែលមានលក្ខណៈទេសភាពធម្មជាតិ។

៣. តំបន់ប្រើប្រាស់ដោយចីរភាព៖ គឺជាតំបន់គ្រប់គ្រងដែលមានតម្លៃសេដ្ឋកិច្ចបម្រើដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ការគ្រប់គ្រង ការអភិរក្សតំបន់ការពារធម្មជាតិផ្ទាល់និងចូលរួមលើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន។

៤. តំបន់សហគមន៍៖ គឺជាតំបន់គ្រប់គ្រងបម្រើឱ្យការអភិវឌ្ឍសេដ្ឋកិច្ចសង្គមកិច្ចរបស់សហគមន៍មូលដ្ឋានដែលមានសកម្មភាពស្រាប់ មានជាអាទិ៍ លំនៅឋាន ស្រែ ចម្ការ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ (ក្រសួងបរិស្ថាន និងធនធានធម្មជាតិ, 2023)។

## ១.១. ចំណោទបញ្ហា

ព្រៃឈើនៅកម្ពុជាមានទំនាក់ទំនងយ៉ាងជិតស្និតជាមួយនឹងវិស័យកសិកម្មផលផល មិនតែប៉ុណ្ណោះព្រៃឈើបានបម្រើឱ្យប្រជាពលរដ្ឋប្រមាណ ៧៥ភាគរយ ជាគ្រួសារដែលគ្មានដីស្រែ គឺពឹងផ្អែកទៅលើការប្រមូលផលពីធនធានព្រៃឈើសម្រាប់ចិញ្ចឹមជីវិតពិសេសពេលជួបគ្រោះធម្មជាតិ។ ធនធានព្រៃឈើមានលក្ខណៈជីវសាស្ត្រពិសេសប្លែក និងជាតំបន់មរតកវប្បធម៌ជាតិដែលមានសក្តានុពលនិងផ្តល់ទិន្នផលខ្ពស់។ សេវាកម្មព្រៃឈើរួមមានទាំងការរក្សានិយ័តភាពប្រភពទឹកចរន្តទឹក ការទប់ស្កាត់ភាពរាំងស្ងួត និងទឹកជំនន់ ការកាត់បន្ថយការហូរច្រោះដី ការរាក់គោកនៃទន្លេ-ស្ទឹង-អូរ-បឹងបួរ។ល។ ដូច្នេះព្រៃឈើមានតួនាទីសំខាន់ក្នុងការអភិវឌ្ឍជាតិប្រកបដោយចីរភាព។

ការប្រើប្រាស់ព្រៃឈើប្រកប ដោយនិរន្តរភាពអាចផ្តល់ប្រយោជន៍យ៉ាងច្រើនដល់ប្រទេសជាតិ និងប្រជាជន។ ឱកាសជាច្រើនកំពុងតែកើតមានឡើងនៅលើទីផ្សារអន្តរជាតិ ដូចជាការកែច្នៃផលិតផលព្រៃឈើដែលមានតម្លៃខ្ពស់ និងសក្តានុពលនៃការអភិវឌ្ឍទីផ្សារកាបូនព្រៃឈើជាដើម។ ប្រភពហិរញ្ញវត្ថុថ្មីៗ កំពុងត្រូវបានគេបង្កើតឡើងតាមរយៈយន្តការ“ការបង់ថ្លៃសេវាកម្មបរិស្ថាន” សម្រាប់ការអភិ

រក្សធនធានព្រៃឈើ និងជីវចម្រុះ (កម្មវិធីព្រៃឈើជាតិ, ២០១០)។ ព្រៃឈើ ក៏បានផ្តល់អំណោយផលដល់ប្រជាកសិករផងដែរនូវឱកាសក្នុងការដាំដុះដំណាំចម្រុះការរកប្រាក់ចំណូលបន្ថែមនិងការបង្កើតការងារដោយសហគ្រាសផលិតកម្មអនុផលព្រៃឈើ។

ជាការកត់សម្គាល់ ស្ថានភាពគម្របព្រៃឈើនៅកម្ពុជាមានការថយចុះពីមួយឆ្នាំទៅមួយឆ្នាំ ព្រមជាមួយគ្នានឹងការអង្កេតនេះដែរ អង្គការទិន្នន័យអំពីការអភិវឌ្ឍ (ODC) បានបង្ហាញក្រាហ្វដែលបង្ហាញពីផ្ទៃដីសរុប និងភាគរយនៃគម្របព្រៃឈើរបស់ប្រទេសកម្ពុជាបានថយចុះបន្តិចពី៤៣,២១ភាគរយក្នុងឆ្នាំ២០១៥ដល់៣៩,៧៥ភាគរយក្នុងឆ្នាំ២០២៣ (ODC, 2023)។

ទិន្នន័យនៃបច្ចុប្បន្នភាពគម្របព្រៃឈើនេះហាក់នៅឆ្ងាយពីគ្គីរំពឹងទុកដែលមានចែងក្នុងអាទិភាពទី២នៃយុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន ២០២៣-២០២៨ ក្នុងន័យដើម្បីពង្រីកគម្របព្រៃឈើឈានឆ្ពោះទៅគោលដៅ៦០ភាគរយនៅឆ្នាំ ២០៥០ (យុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន, ២០២៣)។

ចំពោះតំបន់ការពារដែលឋិតក្នុងខេត្តព្រះវិហារមានសហគមន៍ប្រមាណ៤១ សហគមន៍។ ក្នុងចំណោមសហគមន៍ទាំងនោះភាគច្រើនប្រកបរបរប្រមូលជ័រច្បោះព្រោះរបរនេះអាចផ្តល់ប្រាក់ចំណូលបន្ថែមដល់សមាជិកសហគមន៍សម្រាប់ផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ (Dara, 2021)។

### ១.២.និយមន័យ៖ ដើមច្បោះជាអ្វី?

ជនជាតិដើមភាគតិចកួយអាចប្រមូលអនុផលព្រៃឈើពីជ័រច្បោះម្តងៗបានចាប់ពី៣ ទៅ៤កាន ដែលក្នុងមួយ កានមានចំណុះ ៣០ លីត្រ ឬក៏លើសពីនេះទៅតាមដើមច្បោះដែលមាន។ ជាទូទៅបងប្អូនដែលទៅដងជ័រច្បោះត្រូវចំណាយពេលប្រហែលជា២យប់៣ថ្ងៃក្នុងការចូលព្រៃ ដើម្បីប្រមូលផល ហើយពួកគាត់អាចលក់ជ័រច្បោះទៅឱ្យឈ្មួញកណ្តាលបានមួយកានចាប់ពីតម្លៃ ៧ ម៉ឺនរៀល ទៅដល់ ៨ម៉ឺនរៀល ដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារដែលរដូវកាលខ្លះតម្លៃជ័រអាចឡើងដល់

១០ម៉ឺនរៀល ឬ១២ម៉ឺនរៀលឯណោះ។ ប៉ុន្តែតម្លៃទីផ្សារពីការលក់ជ័រច្បោះនេះគឺតែងតែមានការប្រែប្រួលទៅតាមតម្លៃដែលឈ្មួញកណ្តាលដាក់តម្លៃ។ មុខរបរដងជ័រច្បោះគឺជាមុខរបរមួយដ៏សំខាន់របស់សហ-គមន៍មូលដ្ឋាន ភាគច្រើនជាព្រះរការឱ្យទៅកូនចៅរបស់ពួកគាត់តពីមួយជំនាន់ ទៅមួយជំនាន់ដើម្បីប្រកបរបរចិញ្ចឹមជីវិតជាប្រចាំថ្ងៃផងដែរ។ កម្រៃបានពីការដងជ័រច្បោះនេះហើយដែលបានចិញ្ចឹមជីវិតកុមារ និងមនុស្សជាច្រើនរយគ្រួសារដែលតាំងទីលំនៅក្បែរតំបន់



*រូបភាពទី 2 ជនជាតិដើមភាគតិចកួយកំពុងដងជ័រទឹក*

ជនជាតិដើមភាគតិចកួយដែលបានបន្សល់ទុកតាំងពីដូនតារបស់ពួកគេ លើសពីនេះទៀតជនដើមភាគតិចកួយក៏បានថែកេរមរតដើមជ័រច្បោះដែលមាននៅក្នុងព្រៃការពារនោះ។

តាមការចំណាំជាទូទៅរបស់ប្រជាសហគមន៍បានឱ្យដឹងថា ជ័រច្បោះអាចទាញចេញពីឈើ០២ប្រភេទ គឺត្រាច និង

ឈើទាល ដែលលក្ខណៈខុសគ្នារវាងឈើទាំង០២ប្រភេទនេះមានដូចការរៀបរាប់ខាងក្រោម៖

១. ត្រាចមាន០២ប្រភេទ៖

ក) ត្រាចស ៖ មានផ្កាលឿងឆ្នូតសៗតូចៗ មានខ្លឹមសស្រគាំ;

ខ) ត្រាចក្រហម៖ មានផ្កាក្រហមធំៗ មានខ្លឹមក្រហម។ ជ័រដែលបានពីដើមត្រាចមានគុណភាពល្អ។

២. ឈើទាល០៣ប្រភេទខុសៗគ្នាទៀត៖

ក) ឈើទាលបាយ៖ លក្ខណៈ: សម្គាល់គឺជ័រលាយពណ៌សកកៗដុំៗ ស្លឹកធំ។

ខ) ឈើទាលប្រេង៖ លក្ខណៈ: សម្គាល់ជ័រមានពណ៌ខ្មៅដូចប្រេងម៉ាស៊ីន និងស្លឹកធំ។

គ) ឈើទាលបង្គួយ៖ លក្ខណៈ: សម្គាល់ស្លឹកតូចៗ ដើមវិញមានរពីករពកច្រើន។

អត្ថប្រយោជន៍របស់ជ័រច្បោះ គឺត្រូវបានគេយកទៅលាយជាមួយជ័រចុង ទុកសម្រាប់បិត ឬក៏លាបទូកការពារកុំឱ្យជ្រាបទឹក និងប្រើសម្រាប់ធ្វើជាគប់ភ្លើង ឬចន្លុះ។ សម្រាប់ជ័រចុងជាជ័រដែលបានពីដើមថ្នឹក ដែលវាហៀរមកដោយឯកឯង ហើយក្លាំងនៅតាមដើម។

## ១.៣ ប្រវត្តិដែនជម្រកសត្វព្រៃព្រះរការ

ព្រៃព្រះរការមានទំហំ៩០ ៣៦១ ហិកតាស្ថិតនៅក្នុងស្រុកចំនួនបីនៃខេត្តព្រះវិហារ គឺស្រុកជាំក្សាន្ត ស្រុកឆែប និងស្រុកត្បែងមានជ័យ។ ព្រៃព្រះរការត្រូវបានរដ្ឋាភិបាលដាក់បញ្ចូលជាដែនជម្រកសត្វព្រៃនៅថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៦ យោងតាមអនុក្រឹត្យលេខ៧៥អនក្របក នៅក្នុងគោលបំណងដើម្បី៖

- ធានាការការពារជម្រកសត្វព្រៃ និងប្រព័ន្ធអេកូឡូស៊ី និងបំពេញលក្ខខណ្ឌសម្រាប់ប្រភេទសត្វ និងសត្វជាក់លាក់ និងជីវចម្រុះ
- ចែកចាយផលិតផលនិងសេវាកម្មធម្មជាតិសម្រាប់ការប្រើប្រាស់ប្រកបដោយនិរន្តរភាព
- លើកកម្ពស់សហគមន៍មូលដ្ឋាន និងការគ្រប់គ្រងធនធានជាតិដែលមាន

មូលដ្ឋានលើសាធារណៈ និងការ
ការពារជីវចម្រុះក្នុងតំបន់[1]។

អ្នកភូមិចាស់ទុំបានដំណាលថា កាលពីដើមឡើយតំបន់នេះបងប្អូនជនជាតិដើមភាគតិចកួយនាំគ្នាហៅថា "ព្រៃធំ" ជាភាសាខ្មែរ ចំណែកភាសាកួយប្រែថា" កោះពីត"។ ថ្ងៃមួយមានព្រានព្រៃម្នាក់បានចូលទៅដើរបណ្តើរសត្វនៅក្នុងព្រៃរហូតដល់ចំណុចមួយមានប្រាសាទ ដែលមានបីទិស ប្រៀបដូចជាមុំ ចង្ក្រាន។ ស្ថិតនៅចំកណ្តាលនៃប្រាសាទនោះមានទឹកត្រពាំងមួយ ហើយនៅក្បែរត្រពាំងនោះគឺមានដើមរការយ៉ាងធំមួយផងដែរ។ បន្ទាប់ពីព្រានព្រៃប្រមាញ់បានសត្វរួចមក គាត់ក៏បន្តដំណើរទៅដល់ទឹកត្រពាំងនោះ ហើយគាត់ក៏វង្វេងផ្លូវរកច្រកចេញមិនរួចសោះរហូតអស់កម្លាំងក៏ប្រាសដេកមួយស្របក់ទៅ។ តាមរឿងដំណាលនោះ បានឱ្យដឹងថា ខណៈកំពុងតែដេកលក់ មានអ្នកតាបានចេញមកពន្យល់មាណពនៅក្នុងសុបិន្តថា ប្រសិនបើចង់ទៅផ្ទះវិញ ទាល់តែកុំយកសត្វចេញពីតំបន់មួយនេះ។ បន្ទាប់ពីភ្ញាក់ពីដំណេក សត្វដែលគាត់រកបានទាំងប៉ុន្មានគាត់ក៏រក្សាវាទុកនៅទីនោះ ដោយមិនបានយកមកផ្ទះឡើយ រំពេចនោះគាត់ក៏អាចរកឃើញផ្លូវធ្វើដំណើរត្រឡប់មកផ្ទះវិញឃើញ។ ហើយចាប់តាំងពីថ្ងៃនោះមក គេ



*រូបភាពទី 3 ពីដុងឬកានសម្រាប់ដាក់ជ័រចេញ្ចពេលកំពុងប្រមូលផល*

នាំគ្នាប្តូរពីការហៅថាព្រៃធំ មកជាព្រៃព្រះរការរហូតមកដល់សព្វថ្ងៃនេះ។

យ៉ាងណាមិញ តាមការបញ្ជាក់របស់ប្រជាពលរដ្ឋនៅក្នុងតំបន់បានឱ្យដឹងថា បច្ចុប្បន្ននេះគេរកមិនឃើញត្រពាំងដែលមាននៅក្នុងរឿងដំណាលនោះពុំឃើញឡើយ។

[1] អនុក្រឹត្យស្តីពីការបង្កើតដែនជម្រកសត្វព្រៃព្រះរការ

## ២. គោលបំណងនៃការសិក្សាស្រាវជ្រាវ និងវិសាលភាព

ការសិក្សាស្រាវជ្រាវនេះមានគោលបំណង សិក្សាអំពីការប្រែប្រួលវត្តមានដើមច្បោះតំបន់ដែនជម្រកសត្វព្រៃព្រះរការមុនពេលដាក់ចូលជាដែនជម្រកសត្វព្រៃអំឡុងឆ្នាំ២០១៥ និងការវិវត្តចុងក្រោយនៅឆ្នាំ២០២៤។ ព្រមជាមួយគ្នានោះការសិក្សានេះក៏នឹងលើកឡើងអំពីចំនួនដើមឈើជ័រច្បោះដែលនៅសល់ ឈ្វេងយល់អំពីកត្តាដែលនាំឱ្យបាត់បង់ព្រៃឈើ ពិសេសដើមច្បោះ និងពិភាក្សាពីស្ថានភាពប្រែប្រួលនៃគម្របព្រៃឈើឆ្នាំ២០១៥ និងឆ្នាំ២០២៣។

ការសិក្សានេះនឹងធ្វើឡើងជាមួយសហគមន៍ដែលទាញយកប្រយោជន៍ពីដែនជម្រកសត្វព្រៃព្រះរការរួមមានស្រុកត្បែងមានជ័យ ស្រុកឆែប និងស្រុកជាំក្សាន្ត។ យ៉ាងណាក្តីចំពោះការសិក្សាស្រាវជ្រាវនេះមិនទាន់ពង្រីកវិសាលភាពក្នុងការសម្ភាសគ្របដណ្តប់លើគ្រប់ចំនួនគ្រួសារទាំង០៣ស្រុកនៅឡើយទេ។

## ៣. វិធីសាស្រ្តស្រាវជ្រាវ

ក្រុមការងារ ភ.ប.អ បានប្រើប្រាស់វិធីសាស្រ្តសម្ភាសន៍ផ្ទាល់ជាមួយក្រុមគោលដៅចំនួន៣ស្រុករួមមានស្រុកឆែប ស្រុកជាំក្សាន្តនិងស្រុកត្បែងមានជ័យ។ វិធីសាស្រ្ត០២ត្រូវបានអនុវត្តន៍រួមមាន៖

១. ការសម្ភាសន៍ជនបង្គោល(KIIs)៖ ភ.ប.អនឹងជួបសម្ភាសន៍ផ្ទាល់ជាមួយសមាជិកសហគមន៍គោលដៅដែលជាម្ចាស់ច្បោះ និងអ្នកដែលធ្លាប់មានច្បោះ។ ការសម្ភាសត្រូវធ្វើតាមលំហូរសំណួរដូចខាងក្រោម៖

ក.តើអ្នកមានដើមច្បោះប៉ុន្មានដើមនៅអំឡុងឆ្នាំ២០១៥?

ខ.តើបច្ចុប្បន្នអ្នកមានដើមច្បោះប៉ុន្មានដើម?ជាការសង្កេតមើលផ្ទាល់ខ្លួនរបស់អ្នកតើមានការប្រែប្រួលចំនួនដើមច្បោះយ៉ាងដូចម្តេចដែរចន្លោះពីឆ្នាំ២០១៥រហូតដល់ឆ្នាំ២០២៤?

គ. តើអ្នកយល់ថាអ្វីជាកត្តាចម្បងនាំឱ្យមានការប្រែប្រួលវត្តមាន ដើមច្បោះរបស់អ្នក?

| ស្រុក | ភូមិ | ចំនួនសំណាក (គ្រួសារ) |
|---|---|---|
| តៀ្បងមានជ័យ | ប្រមេរ | ០៧ |
| | ស្រែព្រាង | ០៩ |
| | បុស្សធំ | ១០ |
| ឆែប | សង្កែ១ | ០៣ |
| ជាំក្សាន្ត | របុញ | ០៣ |
| សរុប | | ៣២ |

តារាង 1តារាងទី 1 ចំនួនសំណាកដែលបានសម្ភាសន៍

២. ការពិភាក្សាក្រុម (FGD)៖ ជាវិធីសាស្ត្រសិក្សា បែបគុណភាពដែលមានអ្នកចូលរួមជាក្រុម។

ភ.ប.អបានជួបពិភាក្សាក្រុម ជាមួយប្រធានសហគមន៍តាមស្រុក យុវជនសកម្ម និងតំណាងសមាជិកសហគមន៍នៃបណ្តាញព្រៃព្រះរការនៅតាមស្រុកនីមួយៗ ដើម្បីបញ្ជាក់អំពីចំនួនគ្រួសារដែលមានដើមច្បោះ ប្រមូលព័ត៌មានស៊ីជម្រៅអំពីការយល់ឃើញបទពិសោធន៍ និងការសង្កេតទូទៅដែលនាំឱ្យមានការប្រែប្រួលដើមច្បោះផងដែរ។

## ៤.លទ្ធផលនៃការស្រាវជ្រាវ

### ៤.១ លទ្ធផលជំនួបជាមួយសមាជិកសហគមន៍ដែលមានដើមច្បោះ

ផ្អែកតាមការជួបសម្ភាសន៍ផ្ទាល់ជាមួយសមាជិកសហគមន៍ ដែលអនុវត្តន៍តាមវិធីសាស្ត្រដែលរៀបរាប់ខាងលើ យើងទទួលបានចំនួន៣២គ្រួសាររួមមានស្រុកត្បែងមានជ័យមាន២៦គ្រួសារ ស្រុកឆែបមាន០៣គ្រួសារ ស្រុកជាំក្សាន្តមាន០៣គ្រួសារ ដោយឡែកសមាជិកសហគមន៍ដែលភ.ប.អបានសម្ភាសន៍ផ្ទាល់ក៏បានប្រាប់ឱ្យដឹងពីចំនួនគ្រួសារដែលនៅមានវត្តមានដើមច្បោះ និងនៅបន្តទាញយកអនុផលមកទល់សព្វថ្ងៃដែលរួមមាន នៅស្រុកឆែប និងស្រុកជាំក្សាន្តប្រមាណ ២៨ គ្រួសារទៀតបើគិតត្រឹមឆ្នាំ២០២៤នេះ។

### ៤.២ វត្តមានដើមច្បោះ

ជាលទ្ធផលតាមការសម្ភាសន៍ចំនួនសំណាកដែលបានបង្ហាញក្នុងតារាងទី១

ខាងលើភាគច្រើននៃប្រជាសហគមន៍ដែលជាជនជាតិដើមភាគតិចកួយ ជាអ្នកប្រកបរបរដងជ័រច្បោះ និងទាញផល-អនុផលព្រៃឈើសម្រាប់ចិញ្ចឹមជីវិត។ យោងតាមទិន្នន័យដែលទទួលបានចំនួនដើមច្បោះនាពេលបច្ចុប្បន្នមានការថយចុះគួរឱ្យកត់សម្គាល់។

ជាក់ស្តែងចំនួនសំណាកបានបង្ហាញថា ក្នុងឆ្នាំ២០១៥ វត្តមានដើមច្បោះមានចំនួន១៨០៥០ដើម ខណៈពេលដែលនៅក្នុងឆ្នាំ២០២៤មានតែ១៣៦៨០ដើម។ ទិន្នន័យនេះបានបង្ហាញឱ្យឃើញថាក្នុងរយៈពេលជិតមួយទសវត្សរ៍វត្តមានដើមច្បោះក្នុងដែនជម្រកសត្វព្រៃព្រះរការមានការប្រែប្រួលប្រមាណ២៤ភាគរយដែលស្មើនឹង៤៣៧០ដើម។ ការប្រែប្រួលនេះកើតចេញពីកត្តាមួយចំនួនដូចជាបទល្មើសព្រៃឈើខុសច្បាប់ ការទន្ទ្រានដីព្រៃព្រមទាំងការដកហូតសម្រាប់ធ្វើលំនៅដ្ឋាន និងកត្តាធម្មជាតិ ដូចជាដួល បាក់ និងឆេះ។

ការប្រែប្រួលក្នុងរយៈពេលមួយទសវត្សនេះ ធ្វើឱ្យជនជាតិដើមភាគតិចដែលរស់នៅជុំវិញតំបន់ដែនជម្រកសត្វព្រៃព្រះរការមានក្តីបារម្ភជាខ្លាំងអំពីការបន្តបាត់បង់វត្តមានដើមច្បោះជាបន្តបន្ទាប់ទៀត ប្រសិនបើអាជ្ញាធរ និងសហគមន៍មូលដ្ឋានមិនអាចសហការគ្នាដើម្បីការពារដែនជម្រកសត្វព្រៃព្រះរការ។




*រូបភាពទី 4 ក្រាបបង្ហាញពីការប្រែប្រួលវត្តមានដើមជ័រទឹករយៈពេល១ទសវត្សរ៍*

## ៤.៣ កត្តាដែលនាំឱ្យបាត់បង់ដើមច្បោះ

ក្រោយពីប្រទេសកម្ពុជាបានបញ្ចប់សង្គ្រាមស៊ីវិលទាំងស្រុងនៅទសវត្សរ៍៩០។ ប្រទេសកម្ពុជាក៏បានចាប់ផ្តើមបើកចំហរទីផ្សារ ដើម្បីស្តារសេដ្ឋកិច្ច និងការអភិវឌ្ឍឡើងវិញ។ ក្នុងនោះការទាញយក

ធនធានធម្មជាតិគឺជាផ្នែកមួយយ៉ាងសំខាន់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ផ្នែកតាមការសម្ភាសន៍ជាមួយសមាជិកសហគមន៍បានលើកឡើងថាសហគមន៍មូលដ្ឋានចាប់ផ្តើមជួបប្រទះនូវការបាត់បង់ព្រៃឈើរួមទាំងការបាត់បង់ដើមច្បោះជាលក្ខណៈទ្រង់ទ្រាយធំក្រោមសកម្មភាពអាជីវកម្មព្រៃគុបសម្រាប់ក្រុមហ៊ុនព្រៃសម្បទាន ហើយក៏បានបន្ថែមទៀតថាសហគមន៍ចាប់ផ្តើមរងគ្រោះដោយសារគម្រោងដីសម្បទានសេដ្ឋកិច្ចដែលបណ្តាលឱ្យមានការបាត់បង់ដីធ្លី ដីចម្ការដែលជាមុខរបរប្រពៃណីកេរ្តិ៍ដូនតារបស់ជនជាតិដើមភាគតិច។ជនជាតិដើមភាគតិចដែលអាស្រ័យផលចេញពីតំបន់ព្រៃព្រះរការបានបង្ហាញថាការបាត់បង់ដើមច្បោះមានស្ថានភាពក្នុងទម្រង់ខុសៗគ្នា។ បណ្តាញសហគមន៍ព្រៃព្រះរការដែលមានព្រំប្រទល់ខាងស្រុកជាំក្សាន្តបានបង្ហាញពីការបាត់បង់ចំនួនដើមច្បោះតាមរយៈការសាងសង់ផ្ទះរបស់ទាហ៊ានចាប់តាំងពីកំឡុងឆ្នាំ២០១២មកម្ល៉េះ។ អំឡុងឆ្នាំ២០១៦ នៅស្រុកត្បែងមានជ័យ និងស្រុកឆែបបានបាត់បង់ដើមច្បោះក្រោមរូបភាពលួចកាប់បំផ្លាញខុសច្បាប់ និងការលួចកាប់ផ្តួលពីសំណាក់ជនល្មើស និងការកាប់រានព្រៃមកទល់សព្វថ្ងៃ។ ក្រៅពីនោះការប្រែប្រួលវត្តមានដើមច្បោះក៏កើតឡើងពីកត្តាធម្មជាតិផងដែរ រួមមាន ខ្យល់ កន្ត្រាក់ ដួលរលំ និងភ្លើងឆេះជាដើម។



*រូបភាពទី 5 គុយដែលសហគមន៍ធ្លាប់ប្រមូលផលចេញពីដែនជម្រកសត្វព្រៃព្រះរការ*



*រូបភាពទី 6 ការកាប់បំផ្លាញព្រៃឈើនៅក្នុងដែនជម្រកសត្វព្រៃព្រះរការ*

## ៤.៤ ទំនាក់ទំនងដើមច្បោះ និងជីវភាពប្រជាជន

មុនឆ្នាំ២០១០បណ្ដាញសហគមន៍ព្រៃព្រះរការស្ទើរតែគ្រប់គ្រួសារ គឺមានដើមច្បោះជ័រច្បោះគ្រប់ៗគ្នា យ៉ាងតិចបំផុតគឺ២០០ដើម ហើយអ្នកដែលមានច្រើនបំផុត គឺរាប់ពាន់ដើមឯណោះ។ មួយលើកៗសមាជិកសហគមន៍អាចរកចំណូលតាមរយៈការដងជ័រច្បោះយ៉ាងតិចចន្លោះពី ២០ទៅ៣០កាន ដែលក្នុងមួយកានមានតម្លៃចន្លោះពី ៨០ ០០០ រៀលទៅ១២០ ០០០ រៀលអាស្រ័យលើទីផ្សារជាក់ស្ដែង។ ស្ថានភាពជីវភាពរបស់សហគមន៍ជនជាតិដើមភាគតិចកួយរស់នៅជុំវិញព្រៃព្រះរការពិតជាមានជីវភាពធូរធារណាស់កាលពីមុនដែលពួកគាត់អាចមានលទ្ធភាពបញ្ជូនកូនឱ្យទៅសាលារៀន និងមិនមានគ្រួសារណាជំពាក់បំណុលធនាគារឡើយដែលស្ថានភាពជីវភាពសហគមន៍ពេលនោះគឺពិតជាខុសពីស្ថានភាពជីវភាពសព្វថ្ងៃនេះខ្លាំងណាស់។

## ៤.៥ ការពិភាក្សាលើស្ថានភាពគម្របព្រៃឈើឆ្នាំ២០១៥ និងឆ្នាំ២០២៣

ការសិក្សាស្រាវជ្រាវនេះក្រុមការងារបានប្រើប្រាស់ទិន្នន័យ ដែលមានប្រភពចេញពីអង្គការទិន្នន័យអំពីការអភិវឌ្ឍ (ODC) ក្នុងឆ្នាំ២០១៥ និងទិន្នន័យដែលមានបច្ចុប្បន្នភាពចុងក្រោយគេគឺឆ្នាំ២០២៣ សម្រាប់មើលពីភាពប្រែប្រួលនៃស្ថានភាពគម្របព្រៃឈើនៅពេលដែលវត្តមានដើមច្បោះមានការថយចុះ។ ក្នុងនេះ ក្រុមការងារបានបែងចែកចេញជា៣តំបន់ក្នុងការពិភាក្សាដែលមានដូចគូសបន្ទាត់ក្រហមព័ទ្ធជុំវិញពណ៌ក្រហម។

១.តំបន់ទី១៖ តំបន់នេះឋិតក្នុងស្រុកជាំក្សាន្ត បើមើលតាមផែនទីឃើញមានការប្រែប្រួលគួរឱ្យកត់សម្គាល់ក្នុងរយៈពេលប្រមាណ១ទសវត្សរ៍នេះ។ ការប្រែប្រួលពីស្ថានភាពគម្របព្រៃឈើ ជាទូទៅអាចសន្និដ្ឋានថាជាការបាត់បង់វត្តមានព្រៃឈើ។ ការបាត់បង់នេះអាចមកពីកត្តាសង្គម(បទល្មើសខុសច្បាប់ រានដីព្រៃធ្វើជាចម្ការ ខ្វះការយល់ដឹងពាក់ព័ន្ធនឹងសម្បត្តិធម្មជាតិ និងច្បាប់ស្ដីពីតំបន់ការពារ)កត្តាធម្មជាតិ (ឆេះ ដួល រលំ ខ្យល់កន្ត្រាក់នារដូវវស្សា)។

២.តំបន់ទី២៖ តំបន់នេះមួយផ្នែកឋិតនៅក្នុងស្រុកត្បែងមានជ័យ និងមួយផ្នែកទៀតឋិតក្នុងស្រុកជាំក្សាន្តដែលមានចម្ងាយប្រមាណ១០គីឡូម៉ែត្រ បើវាស់ពីព្រំប្រទល់ព្រៃព្រះរការនៃស្រុកត្បែងមានជ័យ។ តំបន់នោះមានសក្ដានុពលដើមច្បោះ ដែលសហគមន៍អាចអាស្រ័យផលបាន។ ការប្រែប្រួលដែលមើលឃើញក្នុងឆ្នាំ២០២៣ អាចជាលទ្ធផលបានពីការប្រែប្រួលវត្តមានដើមច្បោះ ឬតំបន់នោះរងការលួចកាប់បំផ្លាញពីជនខិលខូច។ មួយផ្នែកទៀត តំបន់ដែលមើលឃើញថាមានការប្រែប្រួល អាចជាលទ្ធផលពីការកែប្រែដីព្រៃទៅជាដីចម្ការ ដែលអាចមានចម្ការចេក ឬចម្ការដំឡូងមីផងដែរ។

៣.តំបន់ទី៣៖ គឺស្ថិតក្នុងស្រុកឆែបក្នុងឆ្នាំ២០២៣ បើមើលតាមស្ថានភាពគម្របព្រៃឈើបានបង្ហាញថា មានសភាពល្អប្រសើរ ន័យនេះអាចសំដៅបានថាការកាប់បំផ្លាញនៅតំបន់នោះមានការថយចុះ។ ដោយឡែកស្ថានភាពជាក់ស្ដែងនៃ

តំបន់នោះ ភាគច្រើនជាប្រភេទព្រៃល្បោះ ព្រៃគុម្ពោធដោយផ្ទុំៗ ដែលងាយនឹងឆេះ (ដោយធម្មជាតិ ឬកត្តាមនុស្ស)នារដូវប្រាំង ហើយចាប់ផ្តើមលូតលាស់ខៀវស្រងាត់ឡើងវិញនាដើមរដូវវស្សា។ ដូចគ្នាដែរ តំបន់នេះជាតំបន់ដែលជាទីជម្រករបស់សត្វដំរីដែលសមាជិកសហគមន៍ឧស្សាហ៍ជួបដាន។

គម្របព្រៃដែលមានពណ៌បៃតងដូចក្នុងរូបភាពខាងលើនេះមិនសំដៅលើព្រៃធម្មជាតិទាំងស្រុងទេវាអាចជាចម្ការចន្ទីដំឡូងមី ស្រូវ ឬដំណាំកសិកម្មផ្សេងទៀត។ ដូច្នេះការប្រែប្រួលតាមរយៈការមើលឃើញនេះអាចជាព្រៃធម្មជាតិ ឬអាចជាការប្រែប្រួលតាមរយៈការប្រើប្រាស់ដីរបស់សហគមន៍។ ការពិភាក្សាគឺផ្តោតតែចំពោះដែនជម្រកសត្វព្រៃព្រះរការ ដែលស្ថិតក្នុងព្រំប្រទល់ខ្មៅប៉ុណ្ណោះ។ ដែនកំណត់នៃការសិក្សានេះគឺមិនទាន់បានលាតសន្ធឹងដល់តំបន់ដែនជម្រកសត្វព្រៃព្រះរការ-ឆែបឡើយ។ ទោះបីជាយ៉ាងណាក្តី ទំហំនៃការប្រែប្រួលផ្នែកខាងលើនៃតំបន់ដែនជម្រកសត្វព្រៃព្រះរការ ដែលរួមបញ្ចូលទៅជាតំបន់ដែនជម្រកសត្វឆែប-ព្រៃព្រះរការហាក់មានការប្រែប្រួលខ្លាំងគួរឱ្យកត់សម្គាល់តាមរយៈរូបភាពដែលអាចមើលឃើញនេះ និងតម្រូវឱ្យមានការយកចិត្តទុកដាក់ខ្ពស់ក្នុងការពង្រឹងយន្តការរក្សាគម្របព្រៃឈើ និងស្តារឡើងវិញ។




*រូបភាពទី 7 ការប្រៀបធៀបគម្របព្រៃឈើឆ្នាំ២០១៥ និងឆ្នាំ២០២៣*

រីឯនៅឆ្នាំ២០២៣ យើងសង្កេតឃើញថារដ្ឋាភិបាលបានដាក់បញ្ចូលដែនជម្រកសត្វព្រៃឆែប និងដែនជម្រកសត្វដែលមានផ្ទៃដីទំហំ ១៩០ ០២៧ហិកតា (មួយសែនប្រាំបួនម៉ឺនម្ភៃប្រាំពីរហិកតា) ដូចមានចែងក្នុងអនុក្រឹត្យលេខ៧៩អនក្រ



*រូបភាពទី ៩ សហគមន៍ចុះពិនិត្យមើលពីការទន្ទ្រានដីព្រៃ*

ព្រៃព្រះរការបញ្ចូលគ្នាដោយមានឈ្មោះថា ដែនជម្រកសត្វព្រៃឆែប-ព្រះរការ កាលពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ កន្លងទៅក្នុងទំហំផ្ទៃដីសរុបចំនួន៣៤៧ ៥៦៨ហិកតា(បីសែនបួនម៉ឺនប្រាំពីរពាន់ ប្រាំរយហុកសិបប្រាំបីហិកតា) គ្របដណ្តប់លើខេត្តព្រះវិហារ និងខេត្តស្ទឹងត្រែង។ គួរបញ្ជាក់ផងដែរថាទំហំនេះបានមកពីការបូកបញ្ចូលគ្នានៃដែនជម្រកសត្វព្រៃឆែប .បក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការបង្កើតដែនជម្រកសត្វព្រៃឆែប និងដែនជម្រកសត្វព្រៃព្រះរការដែលមានផ្ទៃដីទំហំ ៩០ ៣៦១ ហិកតា(ប្រាំបួនម៉ឺនបីរយហុកសិបមួយហិកតា) ដូចមានចែងក្នុងអនុក្រឹត្យលេខ៧៥ អនក្រ.បកចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការបង្កើតដែនជម្រកសត្វព្រៃព្រះរការ និងផ្នែកខ្លះនៃរបៀងអភិរក្សជីវៈចម្រុះឧត្តរ ដែលមានផ្ទៃ

ដីទំហំ៦៧ ១៨០ហិកតា(ប្រាំមួយម៉ឺនប្រាំពីរពាន់មួយរយប៉ែតសិបហិកតា)ដូចមានចែងក្នុងអនុក្រឹត្យលេខ០៧ អនក្រ.បក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ ស្ដីពីការបង្កើតរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ។សូមគូសបញ្ជាក់ផងដែរថានៅក្បែរ និងក្នុងដែនជម្រកសត្វព្រៃទាំងពីរមានការទទួលស្គាល់សហគមន៍តំបន់ការពារធម្មជាតិមុនពេលដាក់បញ្ចូលគ្នាដូចជា៖

១. សហគមន៍តំបន់ការពារធម្មជាតិ" ព្រៃថ្មគោល" ក្នុងដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ស្ថិតនៅភូមិអូរកក់ ឃុំពោធិ៍ ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ ដែលមានទំហំផ្ទៃដីចំនួន ៧៨៣ ហិកតា (ប្រាំពីររយប៉ែតសិបបីហិកតា) យោងតាមប្រកាសលេខ ១១៦ ប្រក ប.ស្ក ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៣។

២.សហគមន៍តំបន់ការពារធម្មជាតិ" បារាយណ៍ខាំកីត" នៃដែនជម្រកសត្វព្រៃ" ឆែប" ស្ថិតនៅភូមិខាំកីត ឃុំកំពង់ស្រឡៅមួយ ស្រុកឆែប ខេត្តព្រះវិហារ ដែលមានទំហំផ្ទៃដីចំនួន ១ ១០៨ ហិកតា(មួយពាន់មួយរយប្រាំបីហិកតា) យោងតាមប្រកាសលេខ ២៦៣ ប្រ.ក ប.ស្ក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៩។

៣. សហគមន៍តំបន់ការពារធម្មជាតិ" ព្រៃពីរល្វែង" នៃដែនជម្រកសត្វព្រៃ" ឆែប" ស្ថិតនៅភូមិកំពង់សង្កែ ឃុំកំពង់ស្រឡៅមួយ ស្រុកឆែប ខេត្តព្រះវិហារ ដែលមានទំហំផ្ទៃដីចំនួន ១ ១៥៣ ហិកតា (មួយពាន់មួយរយហាសិបបីហិកតា) យោងតាមប្រកាសលេខ ២៦៤ ប្រ.ក ប.ស្ក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៩។

៤. សហគមន៍តំបន់ការពារធម្មជាតិ" ត្រពាំងផុង" នៃដែនជម្រកសត្វព្រៃ"ឆែប" ស្ថិតនៅភូមិស្នួង ឃុំកំពង់ស្រឡៅមួយ ស្រុកឆែប ខេត្តព្រះវិហារ ដែលមានទំហំផ្ទៃដីចំនួន ៧៤៤ ហិកតា(ប្រាំពីររយសែសិបបួនហិកតា)យោងតាមប្រកាសលេខ ២៦៥ ប្រ.ក ប.ស្ក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៩។

៥. សហគមន៍តំបន់ការពារធម្មជាតិ" ព្រៃអណ្ដូងដងផ្លិត" នៃដែនជម្រកសត្វព្រៃ"ឆែប" ស្ថិតនៅភូមិដងផ្លិត ឃុំឆែបពីរ ស្រុកឆែប ខេត្តព្រះវិហារ ដែលមានទំហំ

ផ្ទៃដីចំនួន ២ ៤២៨ ហិកតា(ពីរពាន់បួនរយម្ភៃប្រាំបីហិកតា) យោងតាមប្រកាសលេខ ២៦៦ ប្រ.ក ប.ស្ថ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៩។

៦. សហគមន៍តំបន់ការពារធម្មជាតិ “ព្រៃទ័ព”៖ មានទីតាំងស្ថិតក្នុងដែនជម្រកសត្វព្រៃព្រះរការ ស្ថិតក្នុងភូមិក្រឡាពាស ឃុំព្រីងធំ ស្រុកជាំក្សាន្ត នៃខេត្តព្រះវិហារ ដែលមានផ្ទៃដីសរុប ៣ ៤៩១ហិកតា(បីពាន់បួនរយកៅសិបមួយហិកតា) យោងតាមប្រកាសលេខ២៦៦ ប្រ.ក ប.ស្ថ ចុះនៅថ្ងៃទី៣១ ធ្នូ ឆ្នាំ២០២០។

## ៥.សន្និដ្ឋាន

ក្រោយពីតំបន់ព្រៃព្រះរការបានបង្កើតទៅជាដែនជម្រកសត្វព្រៃព្រះរការ នៅថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៦ យោងតាមអនុក្រឹត្យលេខ៧៥ អនក្រ.បក ដែល




*រូបភាពទី 9 ផែនទីបង្ហាញដែនជម្រកសត្វព្រៃឆែប ព្រះរការ*

គ្រប់គ្រងដោយក្រសួងបរិស្ថានអស់ប្រមាណជាង១ទសវត្សរ៍ក៏នៅតែមានបញ្ហាប្រឈមមួយចំនួនក្នុងកិច្ចការពារដែលនាំឱ្យវត្តមានឈើមានតម្លៃ ពិសេសដើមជ័រចេញ្ញាះ(ដើមឈើទាល និងត្រាច) មានការបាត់បង់។ ការបាត់បង់ទាំងនេះបានបណ្តាលឱ្យទិន្នផលដែលសមាជិកសហគមន៍ពោលគឺជនជាតិដើមភាគតិចកួយតែងតែអាស្រ័យផលមានការថយចុះជាហេតុបង្កឱ្យប៉ះពាល់ដល់សេដ្ឋកិច្ចគ្រួសារគួរឱ្យកត់សម្គាល់។ ក្នុងមួយគ្រួសារៗបានឱ្យដឹងថា មានដើមចេញ្ញាះយ៉ាងតិចបំផុត ២០០ដើម និងគ្រួសារខ្លះទៀតមានច្រើនបំផុតដល់ជាងមួយពាន់ដើម ដែលក្នុងមួយកាន (១កាន=៣០លីត្រ)អាចរកចំណូលបានពី៧០០០០រៀល ទៅ៨០០០០រៀល ហើយតាមរដូវខ្លះអាចឡើងដល់១០០ ០០០រៀល ទៅ១២០ ០០០រៀលដែលតម្លៃនេះប្រែប្រួលតាមឈ្មួញកំណត់។

ដោយយោងតាមលទ្ធផលនៃការស្រាវជ្រាវនេះបានបង្ហាញថាក្នុងឆ្នាំ២០១៥ វត្តមានដើមចេញ្ញាះមានចំនួន១៨ ០៥០ដើម ខណៈពេលដែលនៅក្នុងឆ្នាំ២០២៤មាន ១៣ ៨៦០ដើម។ ទិន្នន័យនេះបានបង្ហាញឱ្យឃើញថាក្នុងរយៈពេលជិត១ទសវត្សរ៍ វត្តមានដើមចេញ្ញាះក្នុងដែនជម្រកសត្វព្រៃព្រះរការមានការប្រែប្រួលប្រមាណ២៤ ភាគរយដែលស្មើនឹង៤ ៣៧០ដើម។ ការប្រែប្រួលនេះកើតចេញពីកត្តាមួយចំនួនដូចជាកត្តាសង្គមរួមមានបទល្មើសព្រៃឈើខុសច្បាប់ការទន្ទ្រានដីព្រៃព្រមទាំងការដកហូតសម្រាប់ធ្វើលំនៅដ្ឋាន និងកត្តាធម្មជាតិដូចជាដួល បាក់ និងឆេះ។

ការសិក្សាទៅលើវត្តមានដើមចេញ្ញាះនៃតំបន់ដែនជម្រកសត្វព្រៃព្រះរការជាមួយសមាជិកសហគមន៍ដែលអាស្រ័យផ្ទាល់ពីការដងជ័រចេញ្ញាះបានបង្ហាញថាវត្តមានដើមចេញ្ញាះមានការបាត់បង់ក្រោយពីដាក់បញ្ចូលតំបន់ព្រៃព្រះរការជាដែនជម្រកសត្វព្រៃ។

យោងតាមចំនួនទិន្នន័យដែលទទួលបានចំនួនដើមចេញ្ញាះនាពេលបច្ចុប្បន្នមានការថយចុះគួរឱ្យកត់សម្គាល់។

## ៦.អនុសាសន៍

ដើម្បីជាចំណែកក្នុងការចូលរួមការការពារដើមច្បោះក៏ដូចជាការពារព្រៃឈើសម្រាប់ទាញយកផល-អនុផលព្រៃឈើនាពេលអនាគតក្រុមសិក្សាស្រាវជ្រាវយល់ឃើញថា៖

ក) ក្រសួងបរិស្ថានតាមរយៈមន្ទីរបរិស្ថាន ត្រូវពង្រឹងនូវការអនុវត្តច្បាប់ប្រឆាំងទៅនឹងអ្នកកាប់ឈើខុសច្បាប់ឈ្មួញកណ្តាល និងជនទាំងឡាយណាដែលគប់គិតគ្នានៅក្នុងឧក្រិដ្ឋកម្មព្រៃឈើ

ខ) ក្រសួងបរិស្ថាន គួររៀបចំការធ្វើអធិការកិច្ច និងបង្កើតឱ្យមានយន្តការណ៍នៅក្នុងការឃ្លាំមើល និងទប់ស្កាត់ការប្រព្រឹត្តិអំពើពុករលួយពីសំណាក់មន្ត្រីអនុវត្តច្បាប់ជាមួយឈ្មួញខិលខូច។

គ) សម្របសម្រួល និងឆ្លើយតបរហ័សទៅនឹងសំណើសុំកិច្ចសហការរបស់សហគមន៍ជនជាតិដើមភាគតិចដើម្បីធ្វើសកម្មភាពទប់ស្កាត់បទល្មើសព្រៃឈើ។

ឃ) ផ្តល់នូវមធ្យោបាយប្រកបដោយអត្ថន័យ និងបរិយាប័ន្នដើម្បីគាំទ្រសហគ្រិនបែបសហគមន៍ តាមរយៈការផ្តល់នូវបច្ចេកទេសនៅក្នុងការទាញយកអនុផលព្រៃឈើ និងជំនាញនៅក្នុងការវិភាគពីតម្រូវការទីផ្សារ និងដំណើរការនៃចង្វាក់ផ្គត់ផ្គង់។

ង) រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបើកលំហរសិទ្ធិសេរីភាពដល់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចក្នុងការសហការចុះល្បាតដើម្បីឱ្យពួកគាត់មានទឹកចិត្តបន្តការពារធនធានធម្មជាតិរបស់គាត់ជាបន្តបន្ទាប់ទៀត។

ឆ) បញ្ជ្រាបអត្ថប្រយោជន៍ព្រៃឈើពិសេសបង្ហាញពីអត្ថប្រយោជន៍ជ័រច្បោះនៅក្នុងសហគមន៍ តាមរយៈការផ្សព្វផ្សាយតាមទីប្រជុំជន សាលារៀនដោយបិទបដា។ល។ ដែលជាផ្នែកលើកទឹកចិត្តដល់ម្ចាស់ដើមច្បោះ ក្នុងការការពារបន្តឱ្យនៅបានគង់វង្ស។

ជ) សហគមន៍ យុវជន សមាគម អង្គការសង្គមស៊ីវិលជាមួយនឹងអាជ្ញាធរមូលដ្ឋានគួរតែសហការគ្នាក្នុងការសិក្សា

ស្រាវជ្រាវ ដើម្បីការពារធនធានធម្មជាតិ ដែលជាសម្បត្តិមនុស្សជាតិ។

## ឯកសារយោង


Dara, V. (2021, June 23). *Resin provides boon to local economy*. Retrieved from The Phnom Penh Post: https://www.phnompenhpost.com/national/resin-provides-boon-local-economy

ODC. (2023, ខែកញ្ញា 11). *គម្របព្រៃឈើ (២០១៥-បច្ចុប្បន្ន)*. Retrieved from ODC Cambodia: https://opendevelopmentcambodia.net/km/profiles/forest-cover/forest-cover-2015-present/

ក្រសួងបរិស្ថាន. (២០១០). *កម្មវិធីព្រៃឈើជាតិ*. ក្រសួងបរិស្ថាន.

ក្រសួងបរិស្ថាន. (2023). *ក្រមបរិស្ថាន និងធនធានធម្មជាតិ*. ភ្នំពេញ: ក្រសួងបរិស្ថាន.

ក្រសួងបរិស្ថាន. (២០២៣, វិច្ឆិកា ១៥). *យុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន*. Retrieved from ក្រសួងបរិស្ថាន: https://www.moe.gov.kh/wp-content/uploads/2023/11/...pdf